ICSF សៀវភៅគោលការណ៍ណែនាំ

ICSF Guidebook



# Understanding the Work in Fishing Convention, 2007

# ការយល់ដឹងអនុសញ្ញាការងារក្នុងការនេសាទ ឆ្នាំ២០០៧

International Collective in Support of Fishworkers
www.icsf.net

**ICSF សៀវភៅគោលការណ៍ណែនាំ**

ការយល់ដឹងអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧

**បោះពុម្ពផ្សាយដោយ:**

គម្រោងរួបរួមអន្តរជាតិដើម្បីគាំទ្រកម្មករនេសាទ

ផ្លូវ 27 College, Chennai 600 006, ឥណ្ឌា

ទូរស័ព្ទ: (៩១) ៤៤ ២៨២៧ ៥៣០៣

ទូរសារ: (៩១) ៤៤ ២៨២៥ ៤៤៥៧

អ៊ីមែល: icsf@icsf.net

**លម្អរូបភាពដោយ:**

Sandesh (sandeshcartoonist@gmail.com

**បោះពុម្ពនៅ:**

Nagaraj and Copmany Pvt. Ltd., Chennai

ISBN 978-81-904590-5-5

ICSF 2007

ICSF Guidebook

ICSF សៀវភៅគោលការណ៍ណែនាំ



# Understanding the Work in Fishing Convention, 2007

# ការយល់ដឹងអនុសញ្ញាការងារក្នុងការនេសាទ ឆ្នាំ២០០៧

International Collective in Support of Fishworkers
www.icsf.net

# អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧

សៀវភៅគោលការណ៍ណែនាំនេះមានបំណងផ្តល់ការពិនិត្យមើលរហ័សមួយនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ដែលអនុម័តនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ក្នុងខែមិថុនា ឆ្នាំ២០០៧ នៅក្នុងសន្និសីទពលកម្មអន្តរជាតិ (ILC) លើកទី៩៦ របស់អង្គការពលកម្មអន្តរជាតិ (ILO)។ វាមិនសំដៅលើការផ្តល់នូវការបកស្រាយនៃបទប្បញ្ញត្តិណាមួយនៃអនុសញ្ញា និង វាមិនគួរនៅក្នុងវិធីណាមួយដែលត្រូវបានចាត់ទុកជាការជំនួសសម្រាប់បញ្ញត្តិពិតប្រាកដដែលវាមាននោះទេ។ សៀវភៅគោលការណ៍ណែនាំនេះ គឺ មានបំណងសំខាន់ដើម្បីជួយដល់ភាពមិនដឹងច្បាស់លាស់ទាំងឡាយជាមួយនឹងអនុសញ្ញា និងការធ្វើការងាររបស់អង្គការ ILO និង ILC ដែលទទួលបានការយល់ដឹងពីបញ្ហាពាក់ព័ន្ធនានា។ ជាពិសេស គេសង្ឃឹមថាសៀវភៅគោលការណ៍ណែនាំនេះ នឹងជួយដល់កម្មករនេសាទ និង អង្គការរបស់ពួកគេឲ្យយល់ដឹងពីផលប្រយោជន៍ដែលអាចកើតមាន និងផលប៉ះពាល់នៃអនុសញ្ញាសម្រាប់ការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

**អនុសញ្ញាការងារ ក្នុងការនេសាទ ឆ្នាំ២០០៧**

**ICSF**

**សៀវភៅគោលការណ៍ណែនាំ**



# មាតិកា


## ១. សេចក្តីផ្តើម

* តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ជាអ្វី?... ១០

## ២. អង្គការពលកម្មអន្តរជាតិ (ILO)

* តើអង្គការពលកម្មអន្តរជាតិជាអ្វី?................................ ១៣
* តើអង្គការ ILO ធ្វើការងារអ្វីខ្លះ?..................................... ១៤
* តើរចនាសម្ព័ន្ធរបស់អង្គការ ILO ជាអ្វី?.......................... ១៥
* តើរចនាសម្ព័ន្ធត្រីភាគីរបស់អង្គការ ILO ជាអ្វី?............. ១៦
* តើការណែនាំអ្វីខ្លះដែលអង្គការ ILOត្រូវតែកែលម្អ លក្ខខណ្ឌពលកម្ម?...................................................... ១៦
* តើអង្គការ ILO អនុម័តលើអនុសញ្ញា ឬអនុសាសន៍ ដូចម្តេច?...................................................................... ១៧

## ៣. អង្គការ ILO និងវិស័យនេសាទ

* តើការចូលរួមរបស់អង្គការ ILO ជាមួយវិស័យនេសាទ គឺអ្វីខ្លះ?........................................................................ ២០
* តើអង្គការ ILO បានធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍស្តង់ដារ ពលកម្មថ្មីក្នុងការនេសាទ?.......................................... ២២

## ៤. អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧

* តើអ្វីទៅជាកិច្ចការសំខាន់ពិសេសនៃអនុសញ្ញា ការងារក្នុងការនេសាទឆ្នាំ២០០៧?............................ ២៦

* តើតម្រូវការចម្បងអ្វីខ្លះស្ថិតក្រោមអនុសញ្ញា
ការងារក្នុងការនេសាទឆ្នាំ២០០៧?............................ ២៧
* តើអ្វីខ្លះជាការស្តែងចេញជាក់លាក់នៃអនុសញ្ញា
ដែលសម្រេចបានតាមគោលបំណងទាំងនេះ?........... ២៩
* តើរចនាសម្ព័ន្ធនៃអនុសញ្ញាការងារក្នុងការនេសាទ
ឆ្នាំ២០០៧ ជាអ្វី?........................................................ ៣០
* តើអ្វីទៅជាវិធី 'អនុវត្តជឿនលឿន'?............................ ៣១

## ៥. ការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច

* ហេតុអ្វីបានជាវាសំខាន់ដើម្បីពិចារណាស្តង់ដារពលកម្ម
សូម្បីតែសម្រាប់ការនេសាទទ្រង់ទ្រាយតូចក្តី?............ ៣៥
* តើអ្នកនេសាទសិប្បកម្មនិងទ្រង់ទ្រាយតូច និងនាវា
នេសាទនឹងទទួលបានផលប្រយោជន៍ដូចម្តេចពី
អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧? ............ ៣៦
* តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧
គ្របដណ្តប់គ្រប់ក្រុមនៃអ្នកនេសាទ និងនាវានេសាទ
ដែរ ឬទេ?..................................................................... ៣៧
* តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧
ដែលផលប្រយោជន៍ទាំងអស់នោះចូលរួមចំណែក
ក្នុងសកម្មភាពនេសាទតាមឆ្នេរដូចម្តេច? .................... ៣៩
* តើអ្វីដែលអង្គការអ្នកនេសាទ និងអង្គការសង្គមស៊ីវិល
អាចធ្វើបានដើម្បីធានាថាផលប្រយោជន៍ចំពោះអ្នកនេសាទ

តាមឆ្នេរស្រដៀងគ្នាទៅនឹងផលប្រយោជន៍ដែលអាច
កើតមានចំពោះអ្នកនេសាទស្ថិតក្រោមអនុសញ្ញា
ការងារក្នុងការនេសាទឆ្នាំ២០០៧?............................... ៣៩

## ៦. វិធីបន្ត

* តើអ្វីទៅដែលគេសង្ឃឹមថារដ្ឋជាសមាជិក
ធ្វើបាននូវបញ្ញត្តិនិងសច្ចាប័ននៃអនុសញ្ញាការងារ
ក្នុងការនេសាទ ឆ្នាំ២០០៧?.......................................... ៤២
* តើមានបទប្បញ្ញត្តិពិសេសអ្វីខ្លះទៀតដើម្បីជួយ
ដល់ប្រទេសកំពុងអភិវឌ្ឍន៍អនុវត្តបញ្ញត្តិនៃអនុសញ្ញា
ការងារក្នុងការនេសាទឆ្នាំ២០០៧?............................... ៤៣
* តើអង្គការអ្នកនេសាទ និងអង្គការសង្គមស៊ីវិល
អាចធ្វើអ្វីខ្លះដើម្បីធានាថាអនុសញ្ញាការងារក្នុង
ការនេសាទឆ្នាំ២០០៧ត្រូវបានគេអនុវត្ត?..................... ៤៤

## ៧. សេចក្តីសន្និដ្ឋាន

* ការអង្កេតសន្និដ្ឋានខ្លះៗ............................................. ៤៨

# សេចក្តីផ្តើម

ស្វាគមន៍ អ្នកនៅលើទូក!



## តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ជាអ្វី?

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ដែលបានអនុម័តដោយប្រតិភូរដ្ឋាភិបាល កម្មករ និងនិយោជក(ថៅកែ)នៅឯសន្និសីទពលកម្មអន្តរជាតិ (ILC) របស់អង្គការពលកម្មអន្តរជាតិ (ILO) បានបញ្ញត្តិស្តង់ដារថ្មីសម្រាប់វិស័យនេសាទ។

គោលបំណងនៃអនុសញ្ញា គឺ "ដើម្បីធានាថាអ្នកនេសាទមានលក្ខខណ្ឌការងារសមរម្យនៅលើនាវានេសាទទាក់ទងនឹងតម្រូវការអប្បបរមាសម្រាប់ការងារនៅលើនាវា លក្ខខណ្ឌសេវាកម្ម ការស្នាក់នៅនិងម្ហូបអាហារ សុវត្ថិភាពមុខរបរនិងការការពារសុខភាព ការថែទាំវេជ្ជសាស្ត្រ និងសុវត្ថិភាពសង្គម"។ បញ្ហាថ្មីៗដែលមិនគ្របដណ្តប់ដោយការណែនាំដែលមានស្រាប់ រួមទាំងការធ្វើមាតុភូមិនិវត្តន៍ ការជ្រើសរើសបុគ្គលិក ការថែទាំវេជ្ជសាស្ត្រនៅឯសមុទ្រ សុវត្ថិភាពមុខរបរនិងសុខភាព ការការពារសន្តិសុខសង្គម និង ការអនុលោមតាម និងអនុវត្តច្បាប់ ត្រូវបានដោះស្រាយ។

អនុសញ្ញានេះកំណត់គោលដៅចម្បងគឺរដ្ឋទង់ជាតិ៖ ជារដ្ឋដែលបានចុះបញ្ជីនាវានេសាទរបស់ពួកគេ និងយុត្តាធិការហិរញ្ញកហាត់លើពួកគេដោយមិនគិតអំពីកន្លែងដែលពួកគេនេសាទ។ អនុសញ្ញានេះក៏មានបទប្បញ្ញត្តិសម្រាប់ត្រួតពិនិត្យរដ្ឋកំពង់ផែផងដែរ៖ ជារដ្ឋដែលមានយុត្តាធិការគ្របដណ្តប់លើនាវានេសាទ ដោយមិនគិតពីសញ្ជាតិដែលរាយការណ៍នៅឯកំពង់ផែនេសាទស្ថិតក្រោមយុត្តាធិការរបស់ពួកគេ។

# អង្គការពលកម្មអន្តរជាតិ (ILO)



Employers
និយោជក
(ថៅកែ)
Workers
កម្មករ
ILC
សន្និសីទពលកម្មអន្តរជាតិ
រដ្ឋាភិបាល
Govt.

## តើអង្គការពលកម្មអន្តរជាតិ (ILO) ជាអ្វី?

អង្គការ ILO គឺជាទីភ្នាក់ងារពិសេសមួយរបស់អង្គការសហប្រជាជាតិ (UN) ដែលអភិវឌ្ឍស្តង់ដារអន្តរជាតិនៃសិទ្ធិពលកម្មគ្របដណ្តប់គ្រប់តំបន់ ដូចជាលក្ខខណ្ឌការងារ ឱកាសស្មើគ្នា សន្តិសុខសង្គម ពលកម្មដោយបង្ខំ សេរីភាពនៃការចូលរួមសមាគម និងការរឹតបន្តឹងអាយុអប្បបរមា។

អង្គការ ILO ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩១៩ នៅពេលបញ្ចប់សង្គ្រាមលោកលើកទី១ ដើម្បីស្វែងរកចក្ខុវិស័យមួយជាសាកល ដែលចុងក្រោយសន្តិភាពតែមួយគត់អាចត្រូវបានបង្កើតឡើង ប្រសិនបើវាគេបានដោះស្រាយចំពោះការងារមនុស្សបានសមរម្យ។ អង្គការ ILO បានក្លាយជាទីភ្នាក់ងារឯកទេសដំបូងគេបង្អស់របស់ UN ក្នុងឆ្នាំ១៩៤៦ ហើយនេះគឺជាការបង្កើតដ៏សំខាន់សម្រាប់ការរស់រានតែមួយគត់នៃសន្ធិសញ្ញា Versailles ដែលបាននាំមកនូវសម្ព័ន្ធប្រជាជាតិក្នុងការរស់នៅ។ ក្នុងឆ្នាំ១៩៦៩ នៅថ្ងៃបុណ្យខួបលើកទី៥០របស់ខ្លួន អង្គការ ILO បានទទួលពានរង្វាន់ណូបែលសន្តិភាព។

អង្គការ ILO មានភក្តីចំពោះឱកាសដ៏ល្អសម្រាប់ស្ត្រី និងបុរសក្នុងការទទួលបានការងារសមរម្យ និងផលិតភាពនៅក្នុងលក្ខខណ្ឌនៃសេរីភាព សមធម៌ សន្តិសុខ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ គោលបំណងចម្បងរបស់វាគឺដើម្បីលើកកម្ពស់សិទ្ធិនៅកន្លែងធ្វើការ លើកទឹកចិត្តដល់ឱកាសការងារសមរម្យ ធ្វើឲ្យប្រសើរឡើងនូវការគាំពារសង្គម និងពង្រឹងការពិភាក្សាក្នុងការដោះស្រាយបញ្ហាដែលទាក់ទងនឹងការងារ។

ក្នុងការលើកកម្ពស់យុត្តិធម៌សង្គម និងការទទួលស្គាល់ជាអន្តរជាតិនូវសិទ្ធិមនុស្សនិងពលកម្ម អង្គការបន្តស្វែងរកបេសកកម្មមូលនិធិ ដែលសន្តិភាពពលកម្មគឺជាការសំខាន់ដើម្បីភាពចម្រើនថ្កុំថ្កើង។ សព្វថ្ងៃអង្គការ ILO ជួយជម្រុញឲ្យកើតមានការងារសមរម្យ និងប្រភេទសេដ្ឋកិច្ច និងលក្ខខណ្ឌការងារដែលផ្តល់ការងារដល់មនុស្ស និងកិច្ចការរបស់មនុស្ស ជាបង្គោលរឹងមាំក្នុងសន្តិភាពយូរអង្វែង វិបុលភាព និងភាពចម្រើនជឿនលឿន។

សមាជិករបស់អង្គការ ILO គឺជារដ្ឋ។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ អង្គការ ILO មានសមាជិក ១៨១។

## តើអង្គការ ILO ធ្វើការងារអ្វីខ្លះ?

អង្គការ ILO បង្កើតបទដ្ឋាន(ស្តង់ដារ)ពលកម្មអន្តរជាតិក្នុងទម្រង់នៃអនុសញ្ញា និងអនុសាសន៍ដែលកំណត់ស្តង់ដារអប្បបរមានៃសិទ្ធិពលកម្មជាមូលដ្ឋាន៖ សេរីភាពនៃការចូលរួមសមាគម សិទ្ធិទទួលស្គាល់កិច្ចព្រមព្រៀងរួម ការបំបាត់ពលកម្មដោយបង្ខំ ភាពស្មើគ្នានៃឱកាស និងការដោះស្រាយ និង បទដ្ឋានដទៃទៀតតម្រូវតាមលក្ខខណ្ឌ នៅទូទាំងវិសាលគមទាំងមូលនៃបញ្ហាទាក់ទងនឹងការងារ។

ជាសំខាន់ អង្គការ ILO ធ្វើការដើម្បីកែលម្អលក្ខខណ្ឌពលកម្មក្នុងចំណោមមធ្យោបាយដទៃទៀត ដូចជា ការកំណត់ពេលម៉ោងការងារ ការការពារកម្មករប្រឆាំងនឹងភាពមានជម្ងឺ ជម្ងឺនិងរបួស ដែលកើតឡើងក្នុងពេលបំពេញការងាររបស់ពួកគេ ការការពារកុមារ ការផ្តល់ឲ្យសម្រាប់អាយុច្រើននិងការបង្កួចប្រយោជន៍ ការការពារផលប្រយោជន៍របស់កម្មករនៅពេលឲ្យទៅបម្រើការងារក្នុងប្រទេសដទៃផ្សេងពីប្រទេសរបស់ខ្លួន និងការធានាសន្តិសុខសង្គមសម្រាប់កម្មករ។

អង្គការ ILO ផ្តល់ជំនួយបច្ចេកទេសជាបឋមក្នុងមុខវិជ្ជាដូចជា៖

- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទាវិជ្ជាជីវៈ
- គោលនយោបាយការងារ
- រដ្ឋបាលពលកម្ម
- ទំនាក់ទំនងច្បាប់ពលកម្ម និងឧស្សាហកម្ម
- លក្ខខណ្ឌការងារ
- ការអភិវឌ្ឍគ្រប់គ្រង
- សហប្រតិបត្តិការ
- សន្តិសុខសង្គម
- ស្ថិតិពលកម្ម និង
- សុវត្ថិភាពមុខរបរ និងសុខភាព

អង្គការ ILO ជម្រុញឲ្យមានការអភិវឌ្ឍអង្គការឯករាជ្យរបស់និយោជក(ថៅកែ)និងកម្មករ និងផ្តល់ការបណ្តុះបណ្តាលនិងសេវាប្រឹក្សាដល់អង្គការទាំងនោះ។ នៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាតិ (UN) អង្គការពលកម្មអន្តរជាតិ (ILO) មានរចនាសម្ព័ន្ធត្រីភាគីមួយដែលចូលរួមដោយកម្មករនិងនិយោជកជាដៃគូស្មើភាពគ្នា ជាមួយនឹងរដ្ឋាភិបាលនៅក្នុងការងារនៃអង្គការដឹកនាំរបស់ខ្លួន។

## តើរចនាសម្ព័ន្ធរបស់អង្គការ ILO ជាអ្វី?

អង្គការពលកម្មអន្តរជាតិ(ILO) មាន សន្និសីទពលកម្មអន្តរជាតិ(ILC) គណៈអភិបាល(GB) និងការិយាល័យពលកម្មអន្តរជាតិ។

ILC ជារឿយៗគេហៅថា “សភាអន្តរជាតិនៃពលកម្ម” ប្រជុំរៀងរាល់ឆ្នាំ ក្នុងខែមិថុនា នៅទីក្រុងហ្សឺណែវ។ ប្រតិភូពីរដ្ឋាភិបាលពីរនាក់ និយោជកម្នាក់ និងពីកម្មករម្នាក់ តំណាងរដ្ឋសមាជិកនិមួយៗ។ ស្តង់ដារពលកម្មអន្តរជាតិត្រូវបានគេច្នៃឡើង និងអនុម័តនៅក្នុងសន្និសីទ ILC។ ILC គ្រប់គ្រងកិច្ចការអនុវត្តនៃអនុសញ្ញា និងអនុសាសន៍ថ្នាក់ជាតិផងដែរ។ របៀបវារៈសម្រាប់កិច្ចប្រជុំទាំងអស់របស់ ILC គឺសម្រេចដោយ GB។

GB គឺ ជាក្រុមប្រឹក្សាប្រតិបត្តិរបស់អង្គការ ILO និង ជាក្រុមអ្នកសម្រេចចិត្តជាន់ខ្ពស់របស់វា។ GB គ្រប់គ្រងការអនុវត្តនៃបទដ្ឋាន(ស្តង់ដារ)ពលកម្មអន្តរជាតិ។ វាប្រជុំបីដងក្នុងមួយឆ្នាំ នៅក្នុងទីក្រុងហ្សឺណែវដើម្បីសម្រេចចិត្តលើគោលនយោបាយនៃអង្គការ ILO និងការបង្កើតកម្មវិធីនិងថវិការបស់ខ្លួន រួចហើយដាក់ចូលទៅក្នុងសន្និសីទពលកម្មអន្តរជាតិ (ILC) ដើម្បីអនុម័ត។ វាក៏បានបោះឆ្នោតជ្រើសរើសអគ្គនាយកផងដែរ។ GB ចងក្រងឡើងដោយមនុស្សចំនួន ៥៦នាក់ ២៨នាក់តំណាងរដ្ឋាភិបាល និង១៤នាក់តំណាងថៅកែនិងកម្មករ។ មនុស្សដែលជាតំណាងរដ្ឋាភិបាល ១០នាក់ គឺបានតែងតាំងដោយសមាជិកនៃអង្គការ ILO ដែលជាប្រធាននៃឧស្សាហាកម្មសំខាន់ៗ ដែលកំពុងចូលរួមនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសប្រេស៊ីល ចិន និងឥណ្ឌា។ រចនាសម្ព័ន្ធត្រីភាគីរបស់អង្គការ ILO តំណាងគោលការណ៍ស្មើគ្នាដោយក្រុមនិយោជក(ថៅកែ) កម្មករ និងរដ្ឋាភិបាល។

ការិយាល័យពលកម្មអន្តរជាតិ គឺជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អង្គការ ILO ។ វាជាទីតាំងទំនាក់ទំនងសម្រាប់សកម្មភាពទូទៅរបស់អង្គការ ILO ដែលវារៀបចំក្រោមការពិនិត្យពិច័យរបស់ GB និងស្ថិតក្រោមការដឹកនាំរបស់អគ្គនាយកមួយរូប ដែលគេបានបោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិប្រាំឆ្នាំម្តង។ ការិយាល័យនេះមានបុគ្គលិកចំនួន ១៩០០នាក់ មកពីជាតិសាសន៍លើសពី១១០សញ្ជាតិ នៅទីស្នាក់ការកណ្តាលនៅក្នុងទីក្រុងហ្សឺណែវ និងនៅការិយាល័យនៅមូលដ្ឋានចំនួន៤០ នៅជុំវិញពិភពលោក។

## តើរចនាសម្ព័ន្ធត្រីភាគីរបស់អង្គការ ILO ជាអ្វី?

អង្គការ ILO មានត្រីភាគី ឬបីក្រុម ដែលមានយន្តការសម្រេចចិត្តរួមគ្នា ដោយមានប្រតិភូតំណាងរដ្ឋាភិបាល និយោជក និងកម្មករ រួមគ្នាកំពុងបោះជំហានស្មើគ្នានៅក្នុងសវីរាង្គ និង ក្នុងការងាររបស់ខ្លួនទាំងមូល។ រចនាសម្ព័ន្ធត្រីភាគីរបស់អង្គការ ILO ដាក់ជុំវិញរដ្ឋាភិបាលនៃរដ្ឋសមាជិក និងអង្គការរបស់និយោជក និងកម្មករ។ រដ្ឋធម្មនុញ្ញអង្គការ ILO តម្រូវឲ្យរដ្ឋសមាជិកនិមួយៗបញ្ជូនគណៈប្រតិភូត្រីភាគីទៅកិច្ចប្រជុំរបស់ ILC បញ្ចូលប្រតិភូរដ្ឋាភិបាលពីរនាក់ ប្រតិភូនិយោជកម្នាក់ ប្រតិភូកម្មករម្នាក់ និងទីប្រឹក្សារបស់ពួកគេបីនាក់រៀងៗខ្លួន។ ប្រតិភូនិយោជក និងកម្មករត្រូវបានជ្រើសរើសនៅក្នុងការពិគ្រោះយោបល់ជាមួយនឹងអង្គការជាតិរបស់និយោ-ជក និងកម្មកររៀងៗខ្លួន ដែលក្នុងរឿងនេះ គឺសម្រេចដោយរដ្ឋាភិបាលជាតិរៀងៗខ្លួន។

## តើការណែនាំអ្វីខ្លះដែលអង្គការ ILOត្រូវតែកែលម្អលក្ខខណ្ឌពលកម្ម?

ការណែនាំដែលអង្គការ ILO ធ្វើការកែលម្អលក្ខខណ្ឌពលកម្ម គឺធ្វើតាមទម្រង់បែបបទនៃអនុសញ្ញាពលកម្មអន្តរជាតិ និងអនុសាសន៍ ដែលអនុម័តដោយ ILC ។ ពួកគេលើកកម្ពស់គោលការណ៍ដែលទទួលស្គាល់ជាអន្តរជាតិ និងគោលបំណងនៃគោលនយោបាយសង្គម និងប្រព័ន្ធរួមមួយនៃស្តង់ដារអន្តរជាតិ នៅលើគ្រប់បញ្ហាទាក់ទងនឹងការងារទាំងអស់។ អនុសញ្ញាអង្គការ ILO គឺជាសន្ធិសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិក ILO ។ អនុសាសន៍ គឺជាការណែនាំគ្មានការបង្ខិតបង្ខំ ដែលជា

រៀយៗ ទាក់ទងជាមួយប្រធានបទដូចគ្នានឹងអនុសញ្ញា ដែលបង្កើតគោលការណ៍ណែនាំ តម្រង់ទិសគោលនយោបាយជាតិ និងសកម្មភាព។ ទម្រង់ទាំងពីរមានបំណងដើម្បីពង្រឹងការប៉ះពាល់ស្តីពីលក្ខខណ្ឌការងារ និងការអនុវត្តផ្ទាល់ នៅជុំវិញពិភពលោក។

## តើអង្គការ ILO អនុម័តអនុសញ្ញា ឬអនុសាសន៍ដូចម្តេច?

មុនពេលដែលអនុសញ្ញា ឬអនុសាសន៍ត្រូវបានអនុម័ត សន្និសីទ ILC បង្កើតច្បាប់ ដើម្បីធានាការរៀបចំតាមលក្ខណៈបច្ចេកទេសឲ្យបានហ្មត់ចត់ និងពិគ្រោះយោបល់បានគ្រប់ជ្រុងជ្រោយជាមួយនឹងសមាជិក។ ILC អាចបង្កើតគណៈកម្មការដើម្បីពិចារណា និងរាយការណ៍ពីបញ្ហាដែលពាក់ព័ន្ធ។ របាយការណ៍ដែលគេទទួលបាន សន្និសីទ ILC បានពិចារណាលើអនុសញ្ញាដែលដាក់ស្នើ ឬអនុសាសន៍សម្រាប់ការអនុម័ត។ បញ្ញត្តិនៃអនុសញ្ញា ឬអនុសាសន៍ ក្រោយមកនឹងត្រូវបានបញ្ជូនទៅគណៈកម្មការរៀបចំសម្រាប់ការព្រាងអត្ថបទចុងក្រោយ។ សន្និសីទ ILC នឹងធ្វើការបោះឆ្នោតចុងក្រោយមួយលើការអនុម័តអនុសញ្ញា ឬអនុសាសន៍ក្នុងអត្ថបទចុងក្រោយ ដែលនេះវាទាក់ទងនឹងមាត្រាទី១៩ នៃរដ្ឋធម្មនុញ្ញរបស់អង្គការ ILO។ សម្លេងភាគច្រើនដាច់ខាតពីរភាគបី នៃសម្លេងឆ្នោតដែលបានបោះដោយប្រតិភូមានវត្តមានក្នុងសន្និសីទ ILC គឺចាំបាច់លើការបោះឆ្នោតចុងក្រោយសម្រាប់ការអនុម័តអនុសញ្ញា ឬអនុសាសន៍។

អនុសញ្ញាគឺបើកចំហដើម្បីការផ្តល់សច្ចានុមតិ ឬអនុម័តជាផ្លូវការដោយរដ្ឋាភិបាល។ សមាជិកនិមួយៗដែលផ្តល់សច្ចាប័នអនុសញ្ញា យល់ព្រមធ្វើរបាយការណ៍ប្រចាំឆ្នាំឲ្យទៅការិយាល័យពលកម្មអន្តរជាតិ ស្តីអំពីវិធានការដែលបានដាក់ចេញមានឥទ្ធិពលលើបញ្ញត្តិនៃអនុសញ្ញា ទៅលើអ្វីដែលវាជាដៃគូ ដូចជា ការអភិវឌ្ឍនៃច្បាប់ជាតិ ជាដើម។ រដ្ឋជាសមាជិកក៏មានកាតព្វកិច្ចផងដែរ ធ្វើរបាយការណ៍ស្តីអំពីអនុសញ្ញាដែលពួកគេមិនបានផ្តល់សច្ចាប័ន។

អនុសាសន៍ ទោះជាវាមិនចងក្រងជាច្បាប់ និងមិនបានបង្កើតជាកាតព្វកិច្ចផ្លូវការជាក់លាក់សម្រាប់រដ្ឋាភិបាលក៏ដោយ តែវាជាការណែនាំដល់ការធ្វើគោលនយោបាយសង្គមរបស់រដ្ឋាភិបាល។

# អង្គការ ILO និងវិស័យនេសាទ



Fishing-related Conventions

អនុសញ្ញាទាក់ទងនឹងការនេសាទ

## តើការចូលរួមរបស់អង្គការ ILO ជាមួយវិស័យនេសាទ គឺអ្វីខ្លះ?

សារៈសំខាន់របស់អង្គការ ILO ក្នុងការកែលម្អលក្ខខណ្ឌពលកម្មក្នុងវិស័យនេសាទ ចុះកាលបរិច្ឆេទឆ្នាំ១៩២០ នៅសម័យប្រជុំលើកទី២ នៃសន្និសីទ ILC នៅទីក្រុងហ្សឺណូអា (Genoa) ប្រទេសអ៊ីតាលី បានអនុម័តលើអនុសាសន៍ដែលផ្តោតលើការកំណត់ម៉ោងនៃការងារក្នុងឧស្សាហកម្មនេសាទ។ វាគេបានស្នើឡើង “គឺប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬ៤៨ម៉ោងក្នុងមួយសប្តាហ៍ គឺជាស្តង់ដារដែលគេប្រាថ្នានៅកន្លែងណាដែលវាគេមិនទាន់បានសម្រេចដល់នៅឡើយ”។

ជិត៤០ឆ្នាំក្រោយមក អនុសញ្ញាបីទាក់ទងនឹងការនេសាទត្រូវបានអនុម័តនៅឯសន្និសីទ ILC ដែលមានឈ្មោះថា អនុសញ្ញាអាយុអប្បបរមា (អ្នកនេសាទ) ឆ្នាំ១៩៥៩ (លេខ១១២) អនុសញ្ញាត្រួតពិនិត្យវេជ្ជសាស្ត្រ (អ្នកនេសាទ) ឆ្នាំ១៩៥៩ (លេខ១១៣) និងអនុសញ្ញាក្រមនៃកិច្ចព្រមព្រៀងរបស់អ្នកនេសាទឆ្នាំ១៩៥៩ (លេខ១១៤)។

អនុសញ្ញាលេខ១១២ ដាក់ឲ្យអនុវត្តចំពោះគ្រប់នាវាពាណិជ្ជកម្មនេសាទសមុទ្រទាំងអស់ ហើយហាមឃាត់មិនឲ្យក្មេងអាយុក្រោម ១៥ឆ្នាំធ្វើការនៅលើនាវានេសាទទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសុខភាព និងស្ថានភាពរាងកាយអនុញ្ញាត កុមារអាយុមិនទាបជាង១៤ឆ្នាំអាចជួលឲ្យធ្វើការបាន។

អនុសញ្ញាលេខ១១៣ ក៏បានដាក់ឲ្យអនុវត្តចំពោះគ្រប់នាវាពាណិជ្ជកម្មនេសាទសមុទ្រផងដែរ ប៉ុន្តែលើកលែងនាវាដែលមិនធន់ទ្រាំបាននៅឯសមុទ្រច្រើនជាងបីថ្ងៃ។ វាតម្រូវឲ្យអ្នកនេសាទម្នាក់ (អ្នក ឬ នាង) មានវិញ្ញាបនបត្រមួយ បញ្ជាក់ពីកាយសម្បទាផ្ទាល់ខ្លួនសមស្របសម្រាប់ការងារដែលគេជួលឲ្យធ្វើ។

អនុសញ្ញាលេខ១១៤ បានដាក់ឲ្យអនុវត្តចំពោះនាវាពាណិជ្ជកម្មនេសាទសមុទ្រ ដោយភ្ជាប់ជាមួយនឹងបទប្បញ្ញត្តិស្តីពីប្រភេទនាវានេសាទលើកលែងសំខាន់ៗ ដោយការពិគ្រោះយោបល់ជាមួយតំណាងនិយោជកនិងកម្មករ។ វាតម្រូវតាមមាត្រានៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា

ទាំងភាគីម្ចាស់នាវានេសាទ និងភាគីអ្នកនេសាទ សម្រាប់ភាពទៀងទាត់ ឬមិនទៀងទាត់ រយៈពេល ឬដំណើរនេសាទតាមសមុទ្រ ដោយពិនិត្យទៅលើច្បាប់ជាតិ។ ក្នុងចំណោមការនេសាទដទៃទៀត មាត្រាទាំងនេះសង្កត់ធ្ងន់ពីចំនួនជាក់លាក់នៃបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់អ្នកនេសាទដែលនេសាទតាមសមុទ្រពី របៀប និងចំនួនជាក់លាក់នៃលាភការ និងពីលក្ខខណ្ឌសម្រាប់ការបញ្ចប់នៃកិច្ចព្រមព្រៀង។

នៅក្នុងឆ្នាំ១៩៦៦ អនុសញ្ញានេសាទចុងក្រោយ ដែលចុះកាលបរិច្ឆេទមុនអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ត្រូវបានអនុម័ត។ ទាំងនេះ គឺ អនុសញ្ញាវិញ្ញាបនបត្រសមត្ថភាពរបស់អ្នកនេសាទឆ្នាំ១៩៦៦ (លេខ១២៥) និងអនុសញ្ញាការស្នាក់នៅរបស់នាវិក (អ្នកនេសាទ) ឆ្នាំ១៩៦៦ (លេខ១២៦)។ ការណែនាំទាំងពីរនេះ ក្នុងចំណោមការនេសាទដទៃទៀត លើកលែងចំពោះនាវាដែលនេសាទនៅសមុទ្រខាងក្នុង និងនាវានេសាទបានចុះបញ្ជីថាចំណុះសរុបទាបជាង២៥តោន (GRT)។ អនុ-សញ្ញាក្រោយទៀត ក៏លើកលែងនាវាប្រវែងខ្លីជាង១៣,៧ម។ ជាភស្តុតាងអនុសញ្ញាទាំងពីរនេះ ជាពិសេសបានដាក់ឲ្យអនុវត្តចំពោះប្រតិបត្តិការនេសាទឧស្សាហកម្ម។

អនុសញ្ញាលេខ១២៥ តម្រូវឲ្យរដ្ឋសមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាបង្កើតស្តង់ដារនៃលក្ខណៈសម្បត្តិសម្រាប់បញ្ជាក់សិទ្ធិទទួលយកមនុស្សតាមសមត្ថភាព ដើម្បីបំពេញតួនាទីជាមេបញ្ជាការនាវា ជាសហាជីវិន ឬវិស្វករនៅលើនាវានេសាទ ខណៈដែលអនុសញ្ញាលេខ១២៦ តម្រូវឲ្យពួកគេផ្តល់ឲ្យការស្នាក់នៅបានងាយស្រួលដល់នាវិក។

អនុសញ្ញាបណ្តុះបណ្តាលវិជ្ជាជីវៈ (អ្នកនេសាទ) ឆ្នាំ១៩៦៦ (លេខ១២៦) ផ្តោតលើការបណ្តុះបណ្តាលទូទៅនៃអ្នកនេសាទ នៅក្នុងតំបន់ផ្សេងៗគ្នា ដូចជា ការធ្វើនាវាចរណ៍ ការនេសាទ ការជួសជុល និងថែទាំនាវានេសាទ និង សុវត្ថិភាពនៅឯសមុទ្រ។

អនុសញ្ញាសមុទ្រខ្លះ ក៏មានបទប្បញ្ញត្តិដើម្បីដាក់ឲ្យអនុវត្តចំពោះការធ្វើនេសាទពាណិជ្ជកម្មសមុទ្រផងដែរ។ ដូច្នេះអនុសញ្ញាទទួលខុសត្រូវរបស់ម្ចាស់កប៉ាល់ (កម្មករសមុទ្រឈឺ និងរបួស) ឆ្នាំ១៩៣៦ (លេខ៥៥)

ដាក់ឲ្យអនុវត្តចំពោះនាវានេសាទ លើកលែងតែនាវានេសាទតាមឆ្នេរ។ ស្រដៀងគ្នានេះដែរ អនុសញ្ញាសុខុមាលភាពនៃអ្នកណើរសមុទ្រឆ្នាំ១៩៨៧ (លេខ១៦៣) អនុសញ្ញាការការពារសុខភាព និងការថែទាំវេជ្ជសាស្រ្ត (អ្នកដើរសមុទ្រ) ឆ្នាំ១៩៨៧ (លេខ១៦៤) អនុសញ្ញាសន្តិសុខសង្គម (អ្នកដើរសមុទ្រ) ឆ្នាំ១៩៨៧ (លេខ១៦៥) (កែសម្រួល) អនុសញ្ញាមាតុភូមិនិវត្តន៍នៃអ្នកដើរសមុទ្រ (កែសម្រួល) ឆ្នាំ១៩៨៧ (លេខ១៦៦) អនុសញ្ញាអធិការកិច្ចពលកម្ម (អ្នកដើរសមុទ្រ) ឆ្នាំ១៩៩៦ (លេខ១៧៨) អនុសញ្ញាជ្រើសរើសបន្ថែម និងការដាក់ជំនួសនៃអ្នកដើរសមុទ្រ ឆ្នាំ១៩៩៦ (លេខ១៧៩) និងអនុសញ្ញាម៉ោងការងាររបស់អ្នកដើរសមុទ្រ និងការបើកបរកប៉ាល់ ឆ្នាំ១៩៩៦ (លេខ១៨០) ក៏អាចដាក់ឲ្យអនុវត្តចំពោះការធ្វើនេសាទពាណិជ្ជកម្មសមុទ្រផងដែរ។

## តើអង្គការ ILO បានធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍស្តង់ដារពលកម្មថ្មីក្នុងការនេសាទ?

នៅក្នុងខែមីនា ឆ្នាំ២០០២ សម័យប្រជុំលើកទី២៨៣ របស់ ILO GB ដាក់លើរបៀបវារៈរបស់សន្និសីទ ILC ដែលទាក់ទងនឹងស្តង់ដារដ៏ទូលំទូលាយ៖ គឺអនុសញ្ញាបន្ថែមដោយអនុសាសន៍៖ ស្តីអំពីការងារក្នុងវិស័យនេសាទ។ ស្តង់ដារថ្មី គេប្រកាសកែតម្រូវការណែនាំចំនួន៦ នៃចំនួន៧ ដែលមានស្រាប់របស់អង្គការ ILO ជាមួយនឹងការលើកលែងនៃអនុសញ្ញាវិញ្ញាបនបត្រសមត្ថភាពនៃអ្នកនេសាទ ឆ្នាំ១៩៦៦។ បញ្ហាថ្មីទាក់ទងនឹងមនុស្សដែលធ្វើការងារនៅលើនាវានេសាទ៖ ដូចជាសុវត្ថិភាពមុខរបរ និងសុខភាព និង សន្តិសុខសង្គម ក៏ត្រូវបានគេលើកឡើងដែរ។

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ (C188) ដែលបំពេញបន្ថែមដោយអនុសាសន៍ការងារក្នុងការនេសាទឆ្នាំ២០០៧ (R199) ត្រូវបានអនុម័តនៅក្នុងសម័យប្រជុំលើកទី៩៦ នៃសន្និសីទ ILC ដែលប្រារព្ធធ្វើឡើងនៅក្នុងទីក្រុងហ្សឺណែវ ក្នុងខែមិថុនា ឆ្នាំ២០០៧ បន្ទាប់ពីមានការពិភាក្សាអំពីអត្ថបទស្នើនៃអនុញ្ញា និងអនុសាសន៍នៅក្នុងវគ្គពីរបន្តបន្ទាប់គ្នារបស់គណៈកម្មការ ILC ស្តីអំពី វិស័យនេសាទក្នុងឆ្នាំ២០០៤ និង២០០៥ និងបន្ទាប់មកមានការកែសម្រួលបន្ថែមប្តូរទៅជាអត្ថបទស្នើឡើងដោយរដ្ឋ

សមាជិក និងក្រុមនិយោជក នៅក្នុងគណៈកម្មការ ILC ស្តីពីវិស័យនេសាទ ក្នុងឆ្នាំ២០០៧ វិញ។

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ នឹងចូលជាធរមាននៅក្នុងរយៈពេល១២ខែ បន្ទាប់ពីកាលបរិច្ឆេទលើសច្ចាប័នរបស់សមាជិកចំនួន១០ ដែលក្នុងនោះប្រាំបី គឺជារដ្ឋឆ្នេរសមុទ្រដែលបានចុះបញ្ជីជាមួយអង្គការ ILO។

# អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧

អ្នកនេសាទសមុទ្រទឹកជ្រៅ




នាវាមានគម្លាតទឹក
(នាវាខ្ពស់ពីទឹក)

## តើអ្វីទៅជាកិច្ចការសំខាន់ពិសេសនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧?

ទោះបីជាវាច្រើនជាង៤០ឆ្នាំហើយក៏ដោយមកដល់ពេលនេះ គឺចាប់តាំងពីស្តង់ដារពលកម្មនេសាទអង្គការ ILO ចុងក្រោយត្រូវបានអនុម័ត តែកម្រិតសច្ចាប័ននៃអនុសញ្ញាកន្លងមក គឺនៅទាបខ្លាំងនៅឡើយ។ លើសពីនេះទៀត ការណែនាំចាស់ៗ គឺមិនសមហេតុផលបានពេញលិញយូរនោះទេ គេត្រូវធ្វើបច្ចុប្បន្នភាពវា ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរចរិកលក្ខណៈនៃប្រតិបត្តិការនេសាទសព្វថ្ងៃ។ អនុសញ្ញាសមុទ្រដែលដាក់ឲ្យអនុវត្តចំពោះការនេសាទពាណិជ្ជកម្មសមុទ្រ ក៏ឈប់ទាក់ទងនឹងការអនុម័តអនុសញ្ញាពលកម្មសមុទ្រ (MLC) ឆ្នាំ២០០៦ដែរ ខណៈដែលមានការកែសម្រួលអនុសញ្ញាសមុទ្រដែលមានស្រាប់ បានដកចេញនាវានេសាទពីវិសាលភាពរបស់វា។ អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ កែសម្រួលឡើងវិញនូវស្តង់ដារពលកម្មនេសាទទាំងនេះ និងបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាសមុទ្រ ដែលដាក់ឲ្យអនុវត្តចំពោះនាវានេសាទក្នុងគោលបំណងធ្វើបច្ចុប្បន្នភាព និងពង្រឹងប្រព័ន្ធស្តង់ដារកំណត់ ដើម្បីឆ្លើយតបការផ្លាស់ប្តូរនៅក្នុងវិស័យនេសាទតាំងពីបួនទសវត្សរ៍កន្លងមក និង ដើម្បីបំពេញចន្លោះប្រហោងដោយនាវានេសាទ ដែលមិនបានរាប់បញ្ចូលក្នុងវិសាលភាពរបស់ MLC។

ក្នុងបរិបទថ្មីនៃសេដ្ឋកិច្ច និងពាណិជ្ជកម្មពិភពលោក នាវានេសាទពីប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន កំពុងនេសាទមិនត្រឹមតែនៅក្នុងដែនទឹកប្រទេសរបស់ខ្លួនទេ ប៉ុន្តែនៅក្នុងសមុទ្រទឹកជ្រៅ ក៏ដូចនៅក្នុងដែនទឹកនៃរដ្ឋដទៃផងដែរ។ វាក៏មានការលូតលាស់ដែលមិនធ្លាប់មានពីមុនមកនៅក្នុងការងាររបស់អ្នកនេសាទមកពីប្រទេសកំពុងអភិវឌ្ឍន៍ នៅលើនាវានេសាទរបស់ប្រទេសឧស្សាហកម្មជឿនលឿនផងដែរ។ នៅក្នុងស្ថានភាពទាំងនោះ អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ គឺ ជាឧបករណ៍ដ៏មានប្រយោជន៍មួយ ដើម្បីភ្ជាប់យ៉ាងសំខាន់ជាមួយទំហំពលកម្មនៃការនេសាទដែលបានទទួលស្គាល់ដោយអង្គការ ILO ដូចជា “មុខរបរគ្រោះថ្នាក់ ពេលដែលប្រៀបធៀបនឹងមុខរបរដទៃទៀត” ក៏ដូចជាការកែលម្អស្ថានភាពរស់នៅ និងលក្ខខណ្ឌការងារនៅលើនាវានេសាទ។

សម្រាប់ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃការណែនាំទាក់ទងនឹងការនេសាទរបស់អង្គការ ILO អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ផ្តល់វិសាលភាពដើម្បីពង្រីកទៅគ្រប់ប្រតិបត្តិការនេសាទទាំងអស់ រួមទាំងប្រតិបត្តិការក្នុងទន្លេ បឹង ឬព្រែកជីក ជាមួយនឹងការលើកលែងការនេសាទជាលក្ខណៈគ្រួសារ និងការនេសាទដើម្បីកំសាន្ត។ ជាពិសេស នេះគឺជាការណែនាំទាក់ទងនឹងការនេសាទរបស់អង្គការ ILO លើកដំបូងដែលនាំមកទាំងពីរទាំងប្រតិបត្តិការនេសាទទឹកសាប និងសមុទ្រ រួមទាំងប្រតិបត្តិការនេសាទទ្រង់ទ្រាយតូចផងដែរ នៅក្នុងវិសាលភាពនេះ។ ដូច្នេះអនុសញ្ញានោះដាក់ឲ្យអនុវត្តទាំងពីរទាំងនាវានេសាទទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូច នាវាគ្មានគម្របឃ្លុប និងមានគម្របឃ្លុប ក៏ដូចជាអ្នកនេសាទនៅលើនាវាទាំងនោះ។

## តើតម្រូវការចម្បងអ្វីខ្លះស្ថិតក្រោមអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧?

ប្រទេសដែលផ្តល់សច្ចាប័នអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ ២០០៧ នឹងមានតម្រូវការជាក់លាក់សម្រាប់សុវត្ថិភាពគ្រប់គ្រាន់ក្នុងការបើកបរនាវានេសាទសម្រាប់សុវត្ថិភាពនាវាចរណ៍ និងប្រតិបត្តិការរបស់ពួកគេ។ វានឹងចាំបាច់សម្រាប់សមាជិក ILO ដើម្បីអភិវឌ្ឍស្តង់ដារទាក់ទងនឹង៖

*តម្រូវការអប្បបរមាសម្រាប់ការងារនៅលើនាវានេសាទ*

- អាយុអប្បបរមាសម្រាប់កិច្ចការនៅលើនាវានេសាទ ដោយមិនគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់មនុស្សវ័យក្មេង
- ការត្រួតពិនិត្យវេជ្ជសាស្ត្រ ដើម្បីបញ្ជាក់ច្បាស់ថាអ្នកនេសាទមានកាយសម្បទាគ្រប់គ្រាន់ដើម្បីបំពេញតួនាទីរបស់ពួកគេនៅលើនាវានេសាទ

*ស្ថានភាពសេវាកម្ម*

- សុវត្ថិភាពបើកបរ ដើម្បីឲ្យច្បាស់ថានាវាចរណ៍ និងប្រតិបត្តិការរបស់នាវានេសាទមានសុវត្ថិភាព រយៈពេលទៀងទាត់នៃការ

ឈប់សម្រាកសម្រាប់អ្នកនេសាទនៅលើនាវានេសាទដើម្បីធានាសុវត្ថិភាព និងសុខភាពរបស់ពួកគេ

- ការដាក់តាមបញ្ជីឈ្មោះនាវិកនៅលើនាវានេសាទ និងផ្តល់ច្បាប់ចម្លងនៃបញ្ជីឈ្មោះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចមុននឹងចេញដំណើររបស់នាវា
- ការរៀបចំកិច្ចព្រមព្រៀងការងាររបស់អ្នកនេសាទ និងឯកសារផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធានាការងារសមរម្យ និងលក្ខខណ្ឌរស់នៅសមរម្យដល់អ្នកនេសាទនៅលើនាវានេសាទ
- សិទ្ធិទទួលបានរបស់អ្នកនេសាទសម្រាប់មាតុភូមិនិវត្តន៍ពីកំពង់ផែបរទេស
- ការជ្រើសរើសបន្ថែម និងការជំនួសនៃអ្នកនេសាទ
- យន្តការច្បាស់លាស់ពីការទូទាត់ប្រាក់ឈ្នួលទៀងទាត់ដល់អ្នកនេសាទ

*ការស្នាក់នៅ និងអាហារ*

- បទប្បញ្ញត្តិនៅលើនាវានេសាទដោយគោរពតាមការស្នាក់នៅ អាហារ និងទឹកស្អាត

*ការថែទាំវេជ្ជសាស្ត្រ ការការពារសុខភាព និងសន្តិសុខសង្គម*

- ការថែទាំវេជ្ជសាស្ត្រ និងសិទ្ធិទទួលបានការព្យាបាលវេជ្ជសាស្ត្រលើគោក និងសិទ្ធិបញ្ជូនឡើងគោកទាន់ពេលវេលាក្នុងព្រឹត្តិការគ្រោះថ្នាក់ ឬមានជម្ងឺធ្ងន់
- ការការពារគ្រោះថ្នាក់ក្នុងពេលប្រកបការងារ មានជម្ងឺក្នុងពេលប្រកបការងារ និងហានិភ័យទាក់ទងនឹងការងារនៅលើនាវានេសាទ រួមទាំងការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ
- បណ្តុះបណ្តាលអ្នកនេសាទអំពីរបៀបប្រើប្រាស់ប្រភេទឧបករណ៍នេសាទ និងអំពីចំណេះដឹងផ្នែកប្រតិបត្តិការនេសាទ
- ការរាយការណ៍ និងការស៊ើបអង្កេតគ្រោះថ្នាក់នៅលើនាវានេសាទ
- ធានាថាអ្នកនេសាទ និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ មានសិទ្ធិទទួលបានផលប្រយោជន៍ពីការគាំពារសន្តិសុខសង្គមក្រោមលក្ខខណ្ឌអនុគ្រោះមិនតិចជាងការអនុវត្តនោះចំពោះកម្មករដទៃទៀត ការសម្រេចបានដ៏ទូលំទូលាយនូវការគាំពារសន្តិសុខ

សង្គមសម្រាប់អ្នកនេសាទទាំងអស់ និងដើម្បីធានាការថែទាំនៃសិទ្ធិសន្តិសុខសង្គម

- ការការពារជម្ងឺដែលទាក់ទងនឹងការងារ របួស និងស្លាប់ និងធានាថាម្ចាស់នាវានេសាទទទួលខុសត្រូវសម្រាប់ការផ្តល់ឲ្យទៅអ្នកនេសាទនូវការការពារសុខភាព និងការថែទាំវេជ្ជសាស្ត្រ

*ការអនុលោមតាម និងការអនុវត្តច្បាប់*

- ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃយុត្តាធិការ និងត្រួតពិនិត្យលើនាវាដោយបង្កើតប្រព័ន្ធមួយដើម្បីធានាការគោរពតាមតម្រូវការនៃអនុសញ្ញា។

គ្រប់បទប្បញ្ញត្តិខាងលើនឹងដាក់ឲ្យអនុវត្តចំពោះ៖ (ក).នាវានេសាទប្រវែង២៤ម និងលើស (ខ).នាវានេសាទដែលធន់ទ្រាំបានជាធម្មតានៅឯសមុទ្រច្រើនជាងប្រាំពីរថ្ងៃ ឬ(គ).នាវានេសាទដែលរ៉ាប់រងបានប្រតិបត្តិការនេសាទមានគម្លាតទឹក(នាវាខ្ពស់ពីទឹក)។ ភាគច្រើននៃបទប្បញ្ញត្តិទាំងនោះ នឹងដាក់ឲ្យអនុវត្តផងដែរចំពោះនាវានេសាទ និងអ្នកដែលធ្វើការងារនៅលើនាវានេសាទទាំងនោះ ដោយមិនបានបដិសេធដោយអាជ្ញាធរជាតិពីវិសាលភាពនៃអនុសញ្ញា។

## តើអ្វីខ្លះជាការស្តែងចេញជាក់លាក់នៃអនុសញ្ញាដែលសម្រេចបានតាមគោលបំណងទាំងនេះ?

អនុសញ្ញាមាន៥៤មាត្រា លាតត្រដាងលើប្រាំបួនផ្នែក និងបីឧបសម្ព័ន្ធ។ ផ្នែក I ទាក់ទងនឹងនិយមន័យ (មាត្រា១) និងវិសាលភាព (មាត្រា២, ៣, ៤ និង៥)។ ផ្នែក II ទាក់ទងនឹងគោលការទូទៅ រួមមាន ការអនុវត្ត (មាត្រា៦) អាជ្ញាធរមានសមត្ថកិច្ចនិងការសម្របសម្រួល (មាត្រា៧) និងការទទួលខុសត្រូវរបស់ម្ចាស់នាវានេសាទ មេបញ្ជាការនាវា និងអ្នកនេសាទ (មាត្រា៨)។ ផ្នែក III ទាក់ទងនឹងតម្រូវការអប្បបរមាសម្រាប់ការងារនៅលើនាវានេសាទ រួមមាន អាយុអប្បបរមា (មាត្រា៩) និងការត្រួតពិនិត្យវេជ្ជសាស្ត្រ (មាត្រា១០, ១១ និង១២)។

ផ្នែក IV ទាក់ទងនឹងលក្ខខណ្ឌសេវាកម្ម ផ្នែក V ទាក់ទងនឹងការស្នាក់នៅនិងអាហារ (មាត្រា២៥ ដល់២៨) និងផ្នែក VI ទាក់ទាក់ទងនឹងការ

ថែទាំវេជ្ជសាស្ត្រ ការការពារសុខភាព និងសន្តិសុខសង្គម។ ផ្នែក IV និង ផ្នែក VI គឺជាផ្នែកវែងជាងគេបំផុតនៃអនុសញ្ញា។ ផ្នែក IV រួមមាន ម៉ោងធ្វើការងារនិងម៉ោងឈប់សម្រាក (មាត្រា១៣ និង១៤) បញ្ជីឈ្មោះនាវិក (មាត្រា១៥) កិច្ចព្រមព្រៀងការងាររបស់អ្នកនេសាទ (មាត្រា១៦, ១៧, ១៨, ១៩ និង២០) មាតុភូមិនិវត្តន៍ (មាត្រា២១) ការជ្រើសរើសបន្ថែមនិងការដាក់ជំនួស (មាត្រា២២) និងការចំណាយរបស់អ្នកនេសាទ (មាត្រា២៣ និង២៤)។ ផ្នែក VI រួមមាន ការថែទាំវេជ្ជសាស្ត្រ (មាត្រា២៩ ដល់៣០) សុវត្ថិភាពមុខរបរ និងការការពារសុខភាពនិងការបង្ការគ្រោះថ្នាក់ (មាត្រា៣១ ដល់៣៣) សន្តិសុខសង្គម (មាត្រា៣៤ ដល់៣៧) និងការការពារក្នុងករណីមានជម្ងឺទាក់ទងនឹងការងារ របួស ឬស្លាប់ (មាត្រា៣៨ ដល់៣៩)។

ផ្នែក VII ទាក់ទងនឹងការអនុលោមតាម និងការអនុវត្តច្បាប់ (មាត្រា៤០ ដល់៤៤)។ ផ្នែក VIII ទាក់ទងនឹងវិសោធនកម្មនៃឧបសម្ព័ន្ធ I (សមមូលក្នុងវិធានការ) ឧបសម្ព័ន្ធ II (កិច្ចព្រមព្រៀងការងាររបស់អ្នកនេសាទ) និងឧបសម្ព័ន្ធ III (ការស្នាក់នៅក្នុងនាវានេសាទ)។ ផ្នែក IX ទាក់ទងនឹងអវសានបញ្ញត្តិ។

## តើរចនាសម្ព័ន្ធនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ជាអ្វី?

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ មានរចនាសម្ព័ន្ធពីរផ្នែក។ នៅលើផ្នែកម្ខាងវាមានស្តង់ដារបញ្ញត្តិ៖ (i).សម្រាប់នាវាប្រវែងខ្លីជាង២៤ម និងលើស (ii).សម្រាប់នាវាដែលធន់ទ្រាំនៅសមុទ្របានច្រើនជាងប្រាំពីរថ្ងៃ ឬ (iii).សម្រាប់នាវាដែលធ្វើនាវាចរណ៍បានចម្ងាយលើសពី២០០ន័រទីកាល់ម៉ៃល៍ពីឆ្នេរ ឬ (iv).សម្រាប់នាវាដែលធ្វើនាវាចរណ៍ផុតពីជាយខាងក្រៅនៃទ្វីប និង(v).សម្រាប់អ្នកនេសាទដែលធ្វើការនៅលើនាវា។ នៅលើផ្នែកម្ខាងទៀត វាមានស្តង់ដារអាចបត់បែនបានសម្រាប់នាវានេសាទដទៃទៀតដែលបញ្ជាក់នៅក្នុងវិសាលភាពនៃអនុសញ្ញា និងសម្រាប់អ្នកនេសាទដែលធ្វើការនៅលើនាវាទាំងនោះ។ គេទុកឲ្យរដ្ឋជាសមាជិកអនុម័តវាជាច្បាប់ បទប្បញ្ញត្តិ ឬជាវិធានការផ្សេងទៀត ដើម្បីអនុវត្តបញ្ញត្តិនៃអនុសញ្ញា។ រដ្ឋសមាជិកនឹងត្រូវសម្រេចចិត្តលើប្រភេទនាវានេសាទ រួមទាំងទ្រង់ទ្រាយសិប្បកម្ម និងទ្រង់ទ្រាយតូច ដែលគេគួរតែផ្តល់អនុសាសន៍ចំពោះផលប្រយោជន៍ទទួលបានពីស្តង់ដារពលកម្មនេសាទ។

លើសពីនេះទៀត មានបញ្ញត្តិដើម្បី “អនុវត្តជឿនលឿន” នៃបញ្ញត្តិនៃអនុសញ្ញាដែលទាក់ទងនឹងក្រុមសំខាន់ៗរបស់នាវានេសាទ។

## តើអ្វីទៅជាវិធី ‘អនុវត្តជឿនលឿន’?

ទោះបីជាទស្សនៈនៃ ‘ការអនុវត្តជឿនលឿន’ មិនទាន់បានកំណត់ច្បាស់លាស់នៅឡើយ តែគេយល់ថាវាជាការព្រមព្រៀងមួយដែលចែងក្នុងកិច្ចសន្យាដើម្បីអនុញ្ញាតឲ្យប្រទេសទាំងនោះអនុវត្តបទប្បញ្ញត្តិដែលបញ្ជាក់ពីភាពសំខាន់នៃអនុសញ្ញា (មើលនៅខាងក្រោម) គ្របដណ្តប់លើរយៈពេលវែងមួយ។ អនុសញ្ញាអនុញ្ញាតឲ្យ “ការអនុវត្តជឿនលឿន”បញ្ញត្តិទាំងនេះចំពោះនាវាដែលគេនាំមកនៅក្នុងវិសាលភាពរបស់វា ពីក្រុមដូចតទៅ៖ (i).នាវាប្រវែងខ្លីជាង២៩ម (ii).នាវាមានភារៈចុះសមុទ្រក្នុងរយៈពេលខ្លី ដែលជារឿយៗតិចជាងប្រាំពីរថ្ងៃ និង/ឬ (ii).នាវាដែលមិនអនុវត្តប្រតិបត្តិការនេសាទមានគម្លាតទឹក ក៏ដូចជាចំពោះអ្នកនេសាទដែលធ្វើការនៅលើនាវាទាំងនេះ។ ភាពបត់បែនអនុវត្តជឿនលឿន អាចដាក់ឲ្យអនុវត្តតែចំពោះតម្រូវការនេះ៖

- អ្នកនេសាទកាន់វិញ្ញាបនបត្រវេជ្ជសាស្ត្រមានសុពលភាពបញ្ជាក់ពីកាយសម្បទានៅលើនាវាដែលមាននៅក្នុងក្រុមបីខាងលើ ក៏ដូចជានៅលើនាវានេសាទប្រវែង២៩ម និងលើស ដែលធន់ទ្រាំនៅសមុទ្របានតិចជាងប្រាំពីរថ្ងៃ
- នាវានេសាទដាក់បញ្ជីឈ្មោះនាវិកតាម
- ម្ចាស់នាវានេសាទធានាថាអ្នកនេសាទនិមួយៗមានកិច្ចព្រមព្រៀងការងារដែលចុះហត្ថលេខាទាំងអ្នកនេសាទ និងម្ចាស់នាវានេសាទ ធានាការងារសមរម្យ និងលក្ខខណ្ឌរស់នៅនៅលើនាវា
- ការវាយតម្លៃហានិភ័យដោយមានការចូលរួមរបស់អ្នកនេសាទ
- សមាជិកអង្គការ ILO ផ្តល់ឲ្យអ្នកនេសាទនូវការការពារជម្ងឺដែលទាក់ទងនឹងការងារ របួស ឬស្លាប់ រួមទាំងការទទួលបានការថែទាំវេជ្ជសាស្ត្រ និងសំណងក្នុងព្រឹត្តិការណ៍នៃការរងរបួសដោយសារគ្រោះថ្នាក់មុខរបរ ឬជម្ងឺ តាមរយៈប្រព័ន្ធទទួលខុសត្រូវរបស់ម្ចាស់នាវានេសាទ ឬការធានារ៉ាប់រងមិនអាចខានបាន ឬសំណងរបស់កម្មករ ឬគោលការណ៍ដទៃទៀត។

វិធីអនុវត្តជឿនលឿនផ្តល់ផលប្រយោជន៍ដល់ម្ចាស់នាវានេសាទនៃក្រុមបីខាងលើ ហើយជាពិសេសវាអនុញ្ញាតឲ្យប្រទេសដែលផ្តល់សច្ចាប័នអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាខាងលើឲ្យបានយូរអង្វែង។ វិធីនោះគេសង្ឃឹមថាបានផ្តល់វិភាគទានដ៏ទូលំទូលាយដល់សច្ចាប័ននៃអនុសញ្ញាចាប់តាំងពីវាដោះស្រាយឱនភាពហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័ននៅក្នុងប្រទេសខ្លះដែលអាចរារាំងការអនុវត្តនៃអនុសញ្ញា។

# ការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច

ការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច


ការនេសាទទ្រង់ទ្រាយធំ
Large-scale Fishing
ការនេសាទទ្រង់ទ្រាយតូច
Small-scale Fishing

## ហេតុអ្វីបានជាវាសំខាន់ដើម្បីពិចារណាស្តង់ដារពលកម្ម សូម្បីតែសម្រាប់ការនេសាទទ្រង់ទ្រាយតូចក្តី?

ការអភិវឌ្ឍបច្ចេកវិទ្យាក្នុងវិស័យជលផលចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ បាននាំឲ្យមានយន្តកម្មរីករាលដាលនៃនាវានេសាទ និងប្រតិបត្តិការនេសាទ។ នេះគឺជាលទ្ធផលផងដែរនៅក្នុងនាវានេសាទទ្រង់ទ្រាយតូច និងសិប្បកម្មដែលកំពុងពង្រីកលំដាប់នៃប្រតិបត្តិការនេសាទរបស់ពួកគេ។ ហេតុដូច្នេះហើយទើបមានការផ្លាស់ប្តូរដ៏សំខាន់ ឬ តម្រូវការសម្រាប់ការផ្លាស់ប្តូរលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅនៅលើនាវានេសាទទ្រង់ទ្រាយតូច។

ការប្រកាសតំបន់សេដ្ឋកិច្ចផ្តាច់មុខ២០០នរ័ទីកាល់ម៉ៃល៍ (EEZ) ឬ តំបន់នេសាទផ្តាច់មុខ (EFZ) ដោយរដ្ឋឆ្នេរសមុទ្រមួយចំនួន ចាប់តាំងពីទស្សវត្សរ៍ឆ្នាំ១៩៧០ បានរួមបញ្ចូលជាមួយនឹងបច្ចេកវិទ្យានាវាចរណ៍ជឿនលឿន និងបច្ចេកវិទ្យានេសាទឆ្ពោះទៅរកការពង្រីកឱកាសនេសាទសម្រាប់ទាំងនាវានេសាទទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូច ដែលពុំធ្លាប់មានពីមុនមករបស់រដ្ឋឆ្នេរសមុទ្រនៅក្នុងEEZs/EFZs។ នាវាតូចដែលមានជំនួយនាវាចរណ៍ ឥឡូវបានពង្រីកការធ្វើដំណើរតាមសមុទ្រកាន់តែធំឡើងដើម្បីធានាបានប្រតិបត្តិការនេសាទច្រើនថ្ងៃ ដែលគូសបញ្ជាក់ពីភាពសំខាន់នៃការកែលម្អលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅ ទោះជានៅលើនាវានេសាទទ្រង់ទ្រាយតូច ក៏ដូចគ្នានឹងនាវានេសាទទ្រង់ទ្រាយធំ។ ការរៀបចំនិយោជក និងកម្មករខុសដាច់ពីគ្នា អាចត្រូវបានគេមើលឃើញមាននៅក្នុងនាវាប្រវែងខ្លីជាង២៤ម ដែលកំពុងធ្វើការងារប្រតិបត្តិការនេសាទ។ ដូច្នេះប្រតិបត្តិការនេសាទខ្លះកំពុងតែមានដំណើរវិលឆ្ពោះទៅមុខទៅរកទម្រង់ផលិតកម្មឧស្សាហកម្ម។

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ អាចការពារលក្ខខណ្ឌពលកម្មនៅក្នុងការនេសាទទ្រង់ទ្រាយតូចពីការបន្ធូរបន្ថយ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍វិស័យជលផល។ មានតម្រូវការច្បាស់លាស់មួយសម្រាប់ក្របខ័ណ្ឌច្បាប់ដើម្បីចូលរួមជាមួយលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅនៅក្នុងការនេសាទទូទាំងពិភពលោក សូម្បីតែនៅក្នុងផ្នែកតូចនៃការនេសាទទ្រង់ទ្រាយតូចក្តី។

## តើអ្នកនេសាទសិប្បកម្មនិងទ្រង់ទ្រាយតូច និងនាវានេសាទនឹងទទួលបានផលប្រយោជន៍ដូចម្តេច ពីអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ ២០០៧?

បើទោះបីជាការងារនៅក្នុងអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ ២០០៧ មិនសំអាងជាក់ស្តែងដល់នាវានេសាទទ្រង់ទ្រាយធំ ឬតូច ឬអ្នកនេសាទសិប្បកម្ម ឬនាវានេសាទ ដែលវិសាលភាពរបស់វាគឺ៖ សំដៅដល់ករណីលើកលែង ការឲ្យរួចខ្លួន និងការបដិសេធ នៅជុំវិញប្រតិបត្តិការនេសាទទាំងអស់។ បទប្បញ្ញត្តិនៃអនុសញ្ញាដែលមានសក្តានុពលអាចផ្តល់ផលប្រយោជន៍ដល់នាវានេសាទខ្នាតតូចរួមមាន៖

- ស្តង់ដារអាយុអប្បបរមា
- ការត្រួតពិនិត្យវេជ្ជសាស្ត្រ
- បញ្ជីឈ្មោះនាវិក
- រយៈពេលទៀងទាត់នៃការឈប់សម្រាក
- កិច្ចព្រមព្រៀងការងារ
- ការទូទាត់ទៀងទាត់
- ការស្នាក់នៅ អាហារ និងទឹកស្អាតនៅលើនាវានេសាទ
- បរិក្ខាវេជ្ជសាស្ត្រ និងការផ្គត់ផ្គង់វេជ្ជសាស្ត្រ រួមទាំងតម្រូវការឱ្យមានអ្នកនេសាទម្នាក់នៅលើនាវាដែលបានបញ្ជាក់លក្ខណៈសម្បត្តិ ឬត្រូវបានបណ្តុះបណ្តាលអំពីវិជ្ជាពេទ្យបឋម
- សិទ្ធិទទួលបានការព្យាបាលវេជ្ជសាស្ត្រនៅលើគោក
- ការបង្ការគ្រោះថ្នាក់មុខរបរ ជំងឺមុខរបរ និងហានិភ័យទាក់ទងនឹងការងារនៅលើនាវានេសាទ
- បណ្តុះបណ្តាលអ្នកនេសាទអំពីរបៀបប្រើប្រាស់ប្រភេទឧបករណ៍នេសាទ
- ការរាយការណ៍និងការស៊ើបអង្កេតគ្រោះថ្នាក់នៅលើនាវានេសាទ
- ការការពារសុខភាព និងការថែទាំវេជ្ជសាស្ត្រ និង
- សន្តិសុខសង្គម។

ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច ដែលនឹងទទួលបានផលប្រយោជន៍ពីបញ្ញត្តិខាងលើ នឹងអាស្រ័យលើ ក្នុងចំណោមរឿងផ្សេងទៀត ថាតើក្រុម ឬមិនមែនក្រុមពិសេសណាមួយនៃប្រតិបត្តិការនេសាទទ្រង់ទ្រាយតូច ត្រូវបាននាំមកនៅក្នុងវិសាលភាពនៃអនុសញ្ញា។ ក្រុមទ្រង់ទ្រាយតូចដែលនឹងទទួលបានផលប្រយោជន៍ប្រកបដោយសក្តានុពលពីអនុសញ្ញា នឹងត្រូវបានកំណត់នៅថ្នាក់ជាតិ។

## តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ គ្របដណ្តប់គ្រប់ក្រុមនៃអ្នកនេសាទ និងនាវានេសាទដែរ ឬទេ?

នៅក្រោមអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ និយមន័យនៃពាក្យថា "អ្នកនេសាទ" រួមទាំងមនុស្សដែលបម្រើការងារទាំងអស់ ឬទាក់ទងនឹងសមត្ថភាពណាមួយ ឬបដិបត្តិមុខរបរណាមួយនៅលើនាវានេសាទ រួមទាំងមនុស្សនៅលើនាវាដែលទទួលប្រាក់ឈ្នួល ឬផ្អែកលើមូលដ្ឋាននៃការបែងចែកផលនេសាទ ក៏ដូចជាធ្វើការងារខ្លួនឯង។ ដូច្នេះក្នុងចំណោមអ្នកដទៃទៀត មិនមែនតែអ្នកនេសាទទេ ប៉ុន្តែកម្មករកៃច្នៃត្រីនៅលើនាវានេសាទ ក៏ស្ថិតនៅក្នុងវិសាលភាពនៃអនុសញ្ញាដែរ។ អនុសញ្ញាមានបទប្បញ្ញត្តិលើកលែងប្រតិបត្តិការនេសាទទឹកសាប និងក្រុមសំខាន់ជាក់លាក់នៃអ្នកនេសាទ ឬនាវានេសាទ ចូលរួមក្នុងការនេសាទសមុទ្រ ក្នុងចំណោមរឿងផ្សេងទៀត អាស្រ័យលើប្រវែងនៃនាវានេសាទ រយៈពេលនៃដំណើរនេសាទ តំបន់ប្រតិបត្តិការ និងប្រភេទនៃប្រតិបត្តិការនេសាទ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនាវានេសាទមានប្រវែងក្រោម ២៤ម ការផ្តាច់មុខបែបនេះមិនអាចពង្រីកទៅនាវាដែលធន់ទ្រាំនៅឯសមុទ្របានច្រើនជាងប្រាំពីរថ្ងៃ និងធ្វើនាវាចរណ៍ហួសពី២០០ន័រទីកាល់ម៉ៃល៍ ឬហួសពីគែមខាងក្រៅនៃទ្វីបទេ។


Shore-based Fishers
អ្នកនេសាទ
តាមឆ្នេរ
WFC’07- អនុសញ្ញាកាងារក្នុងការនេសាទ ឆ្នាំ២០០៧
WFC'07
Medical Care
ថែទាំវេជ្ជសាស្ត្រ
ស្ថានភាពសេវាកម្ម
Conditions of Service

## តើអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ដែលផលប្រយោជន៍ទាំងអស់នោះចូលរួមចំណែកក្នុងសកម្មភាពនេសាទតាមឆ្នេរដូចម្ដេច?

និយមន័យនៃអ្នកនេសាទនៅក្នុងអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ មិនរាប់បញ្ចូលការនេសាទតាមឆ្នេរទេ ឬតាមធម្មតាអ្នកនេសាទដែលគ្មានទូក(នាវា)ដូចជា អ្នកជ្រមុជទឹក អ្នកអូសមងតាមឆ្នេរ អ្នកដើររើសសារ៉ាយ និងអ្នកដែលនេសាទដោយប្រើសំណាញ់និងឧបករណ៍នេសាទប្រើប្រាស់នៅតាមឆ្នេរដទៃទៀត និងអ្នកដែលនេសាទដោយប្រើជើងនៅក្នុងតំបន់ទឹកជោរនាច ទោះជាពួកគេនេសាទពេញម៉ោងក្ដី និងទោះជាមានថៅកែ និងក្រុមកម្មករដាច់ស្រឡះពីគ្នាក្នុងចំណោមពួកគេ ក៏ដោយ។

## តើអ្វីដែលអង្គការអ្នកនេសាទ និងអង្គការសង្គមស៊ីវិលអាចធ្វើបានដើម្បីធានាថាផលប្រយោជន៍ចំពោះអ្នកនេសាទតាមឆ្នេរស្រដៀងគ្នាទៅនឹងផលប្រយោជន៍ដែលអាចកើតមានចំពោះអ្នកនេសាទស្ថិតក្រោមអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧?

យុទ្ធនាការថ្នាក់ជាតិគួរតែ ក្នុងចំណោមរឿងផ្សេងទៀត ជួយដល់ការយកចិត្តទុកដាក់របស់រដ្ឋាភិបាលដើម្បីឱ្យអ្នកនេសាទដែលមិនមានទូក អ្នកនេសាទពេញម៉ោង ដូចជាអ្នកជ្រមុជទឹក អ្នករើសខ្យងខ្ចៅ និងអ្នកនេសាទអូសអួនតាមឆ្នេរ ក៏ដូចជាអ្នកដែលចូលរួមនៅក្នុងការងារទាក់ទងនឹងការនេសាទ ជាពិសេសស្ត្រី ដែលមានវត្តមានយ៉ាងសំខាន់ក្នុងសកម្មភាពបែបនេះ ក្នុងគោលបំណងដើម្បីធានាថាពួកគេ ក៏ទទួលបានអត្ថប្រយោជន៍ពីបទប្បញ្ញត្តិនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ នេះផងដែរ។ តម្រូវការអប្បបរមាជាក់លាក់សម្រាប់៖ (i).ការងារគ្រោះថ្នាក់ (ដូចជាការជ្រមុជទឹក ការអូសអួនតាមឆ្នេរនៅក្នុងសមុទ្រដែលមានបាតរដឹបរដុប ឬ ការប្រមូលសំបកខ្យងខ្ចៅនៅក្នុងតំបន់ទឹកជោរនាចហូរក្ដួចខ្លាំង) (ii).ស្ថានភាពនៃសេវាកម្ម (ដូចជាកិច្ចព្រមព្រៀងការងារ ម៉ោងនៃការឈប់សម្រាក ឬ របៀបនៃការទូទាត់) (iii).សុវត្ថិភាពមុខរបរនិងការការពារសុខភាព និង (iv).ការថែទាំវេជ្ជសាស្ត្រនិងសន្តិសុខសង្គម ដែលនឹងជួយធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងស្ថានភាពរស់នៅរបស់អ្នកនេសាទតាមឆ្នេរផងដែរ។

# ទធីបន្ត


Food

## តើអ្វីទៅដែលគេសង្ឃឹមថារដ្ឋសមាជិកធ្វើបាននូវបញ្ញត្តិ និងសច្ចាប័ននៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧?

ប្រទេសដែលផ្តល់សច្ចាប័នអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ ២០០៧ នឹងត្រូវសរសេររបាយការណ៍ទៅអង្គការពលកម្មអន្តរជាតិ (ILO) ប្រាប់ពីមូលហេតុដែលក្រុមសំខាន់នៃអ្នកនេសាទ ឬនាវានេសាទត្រូវបានគេបដិសេធចេញពីវិសាលភាពនៃអនុសញ្ញា និងវិធានការអ្វីដែលត្រូវបានគេយល់ព្រមផ្តល់ការការពារសមមូលទៅនឹងក្រុមបដិសេធ។ ពួកគេត្រូវតែបញ្ជាក់ឲ្យច្បាស់ពីតម្រូវការបន្តទៀតសម្រាប់ភាពគ្រប់គ្រាន់ និងដំណើរការប្រកបដោយសុវត្ថិភាពនៃនាវានេសាទសម្រាប់សុវត្ថិភាពនាវាចរណ៍ និងប្រតិបត្តិការរបស់ពួកគេ និងសម្រាប់សុវត្ថិភាពនិងសុខភាពរបស់អ្នកនេសាទ។ វានឹងចាំបាច់ដើម្បីអភិវឌ្ឍស្តង់ដារដែលទាក់ទង ក្នុងចំណោមរឿងផ្សេងទៀត៖

- រយៈពេលនៃការឈប់សម្រាកគ្រប់គ្រាន់សម្រាប់អ្នកនេសាទធ្វើការនៅលើនាវា ដើម្បីធានាបាននូវសុវត្ថិភាពនិងសុខភាពរបស់ពួកគេ
- យន្តការដើម្បីធានាការទូទាត់ប្រាក់ឈ្នួលទៀងទាត់ដល់អ្នកនេសាទ
- ការផ្តល់ឲ្យនៅលើនាវានេសាទនូវកន្លែងស្នាក់នៅមានទំហំស្រមស្របនិងមានគុណភាព
- ការថែទាំវេជ្ជសាស្ត្រ ដែលយ៉ាងហោចណាស់ត្រូវមានអ្នកនេសាទម្នាក់នៅលើនាវាត្រូវបានបំពាក់បំប៉នសមត្ថភាព ឬបណ្តុះបណ្តាលអំពីការផ្តល់ការថែទាំវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់
- ការទទួលស្គាល់សិទ្ធិអ្នកនេសាទទទួលបានការព្យាបាលវេជ្ជសាស្ត្រនៅលើគោក
- ការបង្ការគ្រោះថ្នាក់មុខរបរ ជម្ងឺមុខរបរ និងហានិភ័យទាក់ទងនឹងការងារនៅលើនាវានេសាទ
- ការផ្តល់អាហារ និងទឹកនៅលើនាវានេសាទដែលមានគុណភាព និងបរិមាណគ្រប់គ្រាន់

- ការបណ្តុះបណ្តាលអ្នកនេសាទអំពីរបៀបប្រើប្រាស់ប្រភេទឧបករណ៍នេសាទ និងចំណេះដឹងអំពីប្រតិបត្តិការនេសាទនៅក្នុងការងារអ្វីដែលពួកគេនឹងចូលរួម
- ការរាយការណ៍ និងការស៊ើបអង្កេតគ្រោះថ្នាក់នៅលើនាវានេសាទ
- ធានាថាអ្នកនេសាទ និងអ្នកដែលនៅក្នុងបន្ទុករបស់ពួកគេមានសិទ្ធិទទួលបានផលប្រយោជន៍ពីការគាំពារសន្តិសុខសង្គម និង
- តម្រូវឱ្យនាវានេសាទអនុវត្តតាមឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចថានាវានេសាទត្រូវតែគោរពតាមបទប្បញ្ញត្តិនៃអនុញ្ញាទាក់ទងនឹងស្ថានភាពរស់នៅ និងលក្ខខណ្ឌការងារ។

ការស្ថិតនៅឆ្ងាយ ដូចជាការគោរពតាមតម្រូវការនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ត្រូវបានគេព្រួយបារម្ភ ហើយរដ្ឋទង់ជាតិគេតម្រូវឱ្យធ្វើអធិការកិច្ច ធ្វើរបាយការណ៍ ត្រួតពិនិត្យតាមដាននិងរឹតបន្តឹងនីតិវិធី ដាក់ពិន័យសមស្រប និងកែប្រែដើម្បីវិធានការត្រឹមត្រូវ។ បន្ទាប់មកមានបញ្ញត្តិរដ្ឋកំពង់ផែឲ្យរាយការណ៍ទៅរដ្ឋទង់ជាតិ ប្រសិនជានាវាដែលនៅឯកំពង់ផែរបស់ខ្លួនមិនបានប្រតិបត្តិតាមតម្រូវការនៃអនុសញ្ញា។ រដ្ឋកំពង់ផែក៏អាចចាត់វិធានការបានដែរ ដើម្បីកែតម្រូវលក្ខខណ្ឌណាមួយនៅលើនាវា ដូចជានាវាដែលគេចាត់ទុកថាអាចមានគ្រោះថ្នាក់ដល់សុវត្ថិភាពឬសុខភាពអ្នកនេសាទ។

## តើមានបទប្បញ្ញត្តិពិសេសអ្វីខ្លះទៀតដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍អនុវត្តបញ្ញត្តិនៃអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧?

"វិធីអនុវត្តជឿនលឿន" (សូមមើលទំព័រ៣១) ផ្តល់នូវភាពបត់បែនបន្ថែមទៀតទៅឲ្យប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងការអនុវត្តបទប្បញ្ញត្តិជាក់លាក់នៃអនុសញ្ញាចំពោះក្រុមនៃនាវានេសាទនិងអ្នកនេសាទនៅលើនាវាទាំងនេះដែលគេនាំយកមកនៅក្នុងវិសាលភាពនៃអនុសញ្ញា។

## តើអង្គការអ្នកនេសាទ និងអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីធានាថាអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ត្រូវបានគេអនុវត្ត?

យុទ្ធនាការដែលគួរតែគេអនុវត្តនៅថ្នាក់ជាតិដើម្បីបញ្ជាក់ច្បាស់ថាអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ត្រូវបានគេផ្តល់សច្ចាប័ន។ គំនិតផ្តួចផ្តើមដើម្បីអភិវឌ្ឍ ឬកែលម្អច្បាប់នៅក្នុងកម្រិតសមស្រប គឺជាការសំខាន់ផងដែរដើម្បីអនុវត្តអនុសញ្ញា។ យុទ្ធនាការនៅថ្នាក់ជាតិដើម្បីស្វែងរកការគាំទ្ររបស់អាជ្ញាធរមានសមត្ថកិច្ច និងអង្គការនិយោជក និងកម្មករ គឺមានសារសំខាន់ណាស់ដើម្បីជួយកំណត់អត្តសញ្ញាណតាមរយៈដំណើរការពិគ្រោះយោបល់និងការចូលរួម ក្រុមនៃអ្នកនេសាទនិងនាវានេសាទដែលគួរតែគេនាំមកនៅក្នុងវិសាលភាពនៃអនុសញ្ញា ឬដែលគួរតែគេបដិសេធនៅក្នុងរយៈពេលខ្លី ឬមធ្យម។ ជាឧទាហរណ៍ វាគឺជាការចាំបាច់សម្រាប់កំណត់អត្តសញ្ញាណនាវានេសាទទាំងអស់ ដោយមិនគិតពីទំហំ ដែលអនុវត្តដំណើរនេសាទច្រើនជាងប្រាំពីរថ្ងៃ ហើយការនេសាទនោះនៅឆ្ងាយពីទ្វីប ឬឆ្ងាយជាង២០០ន័រទីកាល់ម៉ៃល៍។ លើសពីនេះទៀតអ្វីដែលជាប្រភេទនាវានេសាទប្រវែងខ្លីជាង២៤ម និងអ្នកនេសាទដែលធ្វើការងារនៅលើនាវាទាំងនេះ គួរតែគេនាំមកនៅក្នុងវិសាលភាពនៃអនុសញ្ញានឹងអាស្រ័យ ក្នុងចំណោមរឿងផ្សេងទៀត លើរយៈពេលនៃដំណើរនេសាទ តំបន់ប្រតិបត្តិការ និងប្រភេទនៃប្រតិបត្តិការនេសាទ។ បន្ថែមលើនេះទៀត អ្នកនេសាទ និងនាវានេសាទដែលគួរតែគេលើកលែងពី ក៏ដូចជាករណីលើកលែងដែលគួរតែគេធ្វើដើម្បី បញ្ញត្តិខ្លះនៃអនុសញ្ញាគួរតែគេកំណត់អត្តសញ្ញាណ។ វាក៏ចាំបាច់ផងដែរ ដើម្បីកំណត់អត្តសញ្ញាណបញ្ញត្តិនៃអនុសញ្ញាដែលគួរដាក់ឲ្យអនុវត្តចំពោះអ្នកនេសាទទាំងអស់។ ដូច្នេះ ជាឧទហរណ៍ តម្រូវការអាយុអប្បបរមា ការទូទាត់ទៀងទាត់ និងសន្តិសុខសង្គមដែលគេអាចមើលឃើញ ជាបទប្បញ្ញត្តិដែលគួរតែដាក់ឲ្យអនុវត្តចំពោះអ្នកនេសាទទាំងអស់។

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទទួលរងទុក្ខពីហេដ្ឋារចនាសម្ព័ន្ធអាក្រក់ និងស្ថាប័នទន់ខ្សោយ។ ការកសាងសមត្ថភាពអនុវត្តច្បាប់របស់រដ្ឋាភិបាលនឹងត្រូវការការដឹកនាំដ៏ចម្បងមួយ ឬ ការពិនិត្យមើលទៅលើផ្នែកជលផល ផ្នែកសមុទ្រ ឬ អាជ្ញាធរសុវត្ថិភាពនាវានេសាទ និងរដ្ឋបាល

ពលកម្ម។ មានតែការផ្លាស់ប្តូរបែបនេះទេ ដែលអាចជួយឲ្យប្រទេសកំពុងអភិវឌ្ឍន៍ អនុម័តច្បាប់ដើម្បីអនុវត្តអនុសញ្ញាការងារក្នុងការនេសាទ ឆ្នាំ ២០០៧ បាន។ ការនេះគួរតែអាចឲ្យពួកគេអនុវត្តបានផងដែរ នៅលើនាវានេសាទប្រវែងខ្លីជាង២៤ម និង អ្នកនេសាទនៅលើនាវាទាំងនោះ ពីទស្សនវិស័យពលកម្ម ដែលមកដល់ពេលនេះ គេធ្វើបានដោយកម្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ។

# សេចក្តីសន្និដ្ឋាន


UNESCO

## ការអង្កេតសន្និដ្ឋានខ្លះៗ

អនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ផ្តល់ធាតុគន្លឹះនៃស្តង់ដារការងារក្នុងវិស័យនេសាទដែលទាក់ទងទៅនឹងការជ្រើសរើសបន្ថែមនៃអ្នកនេសាទ ការកែលម្អស្ថានភាពរស់នៅនិងលក្ខខណ្ឌការងារនៅលើនាវានេសាទ និងការផ្តល់សន្តិសុខសង្គម។ វាអាចការពារអ្នកនេសាទប្រឆាំងនឹងស្ថានភាពការងារអមនុស្សធម៌ និងគួរតែជួយកែលម្អលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅរបស់អ្នកនេសាទទាំងនៅក្នុងប្រតិបត្តិការនេសាទទ្រង់ទ្រាយធំ និងតូច នៅជុំវិញពិភពលោក។ ខណៈនិយាយអំពីគណៈកម្មការនេសាទឆ្នាំ២០០៧ អគ្គលេខាធិការ នៃសន្និសីទពលកម្មអន្តរជាតិ (ILC) សង្កេតឃើញថា "វាគឺជាការសំខាន់យ៉ាងច្បាស់ណាស់ដែលគ្មានអ្នកនេសាទណាម្នាក់ធ្លាក់ចូលទៅក្នុងការប្រមាថតាមរយៈសំណាញ់ការពារនៃអនុសញ្ញានេះ។ ចំពោះការនេះដើម្បីសម្រេចបានទំហំនៃសំណាញ់នេះ គឺត្រូវតែត្រឹមត្រូវ៖ មិនធំពេកដែលអ្វីៗគ្រប់យ៉ាងត្រូវលើកលែង ប៉ុន្តែក៏មិនតូចពេកដែលវានឹងមិនទន់ភ្លន់ចំពោះការផ្តល់សច្ចាប័ន និងការអនុវត្តន៍"។ រដ្ឋាភិបាល ក្រុមអ្នកនេសាទ និងក្រុមនិយោជក និងអង្គការមិនមែនរដ្ឋាភិបាលគួរតែធ្វើការរួមគ្នា ដើម្បីអនុវត្តអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ នៅទូទាំងពិភពលោក៕


រៀបចំដោយ គម្រោងរួបរួមអន្តរជាតិដើម្បីគាំទ្រកម្មករនេសាទ(ICSF)

Prepared by the International Collective
in Support of Fishworkers (ICSF)

www.icsf.net
icsf@icsf.net

# ការយល់ដឹងអំពីអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧

សៀវភៅគោលការណ៍ណែនាំនេះ ព្យាយាមផ្តល់ការពិនិត្យមើលបានយ៉ាងរហ័សនូវអនុសញ្ញាការងារក្នុងការនេសាទឆ្នាំ២០០៧ ដែលបានអនុម័តនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅក្នុងខែមិថុនា ឆ្នាំ២០០៧ នៅឯសន្និសីទពលកម្មអន្តរជាតិ (ILC) លើកទី៩៦ របស់អង្គការពលកម្មអន្តរជាតិ (ILO)។ វាមិនសំដៅលើការផ្តល់នូវការបកស្រាយនៃបទប្បញ្ញត្តិណាមួយនៃអនុសញ្ញា និងមិនគួរនៅក្នុងវិធីណាមួយដែលត្រូវបានចាត់ទុកជាជំនួសសម្រាប់បញ្ញត្តិពិតប្រាកដដែលវាមាននោះទេ។ សៀវភៅគោលការណ៍ណែនាំនេះ គឺមានបំណងសំខាន់ដើម្បីជួយដល់ភាពមិនដឹងច្បាស់លាស់ទាំងឡាយជាមួយនឹងអនុសញ្ញា និងការធ្វើការងាររបស់អង្គការ ILO និង ILC ដែលទទួលបានការយល់ដឹងពីបញ្ហាពាក់ព័ន្ធនានា។ ជាពិសេស វាត្រូវបានគេសង្ឃឹមថា សៀវភៅគោលការណ៍ណែនាំនេះនឹងជាជំនួយដល់កម្មករនេសាទ និងអង្គការរបស់ពួកគេយល់ដឹងអំពីផលប្រយោជន៍ដែលអាចកើតមាន និងផលប៉ះពាល់នៃអនុសញ្ញាសម្រាប់ការនេសាទសិប្បកម្ម និងទ្រង់ទ្រាយតូច នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍៕

សៀវភៅគោលការណ៍ណែនាំនេះក៏អាចរកបានផងដែរនៅក្នុង
www.icsf.net

ISBN 978 81 904590 51

www.icsf.net